THE SCHOOL DISTRICT OF PHILADELPHIA

FUND OUR SCHOOLS

# ហេតុអ្វីបានជាសាលារៀនសាធារណៈរឹងមាំមានសារៈសំខាន់សម្រាប់មនុស្សគ្រប់គ្នា

> *ការអប់រំ គឺសម្រាប់ការកែលម្អជីវិតរស់នៅរបស់អ្នកដទៃ និងសម្រាប់ធ្វើឲ្យសហគមន៍របស់អ្នក និង ពិភពលោកមានភាពល្អប្រសើរឡើងជាងអ្វីដែលអ្នកធ្លាប់បានជួបពីមុនមក។*
>
> – Marian Wright Edelman

## មិនថាអ្នកមានកូននៅមណ្ឌលសិក្សាធិការនៃទីក្រុង Philadelphia ឬអត់នោះទេ យើងទាំងអស់គ្នាទទួលបានអត្ថប្រយោជន៍ពីសាលារៀនសាធារណៈល្អ។ នេះជាមធ្យោបាយ៖

### ការអភិវឌ្ឍកម្លាំងពលកម្ម និងកំណើនសេដ្ឋកិច្ច

តាមរយៈការអប់រំកុមារគ្រប់រូប – កុមារជួបការលំបាកផ្នែកសេដ្ឋកិច្ច កុមារដែលមានជីវភាពធូរធារ កុមារពិការ និងកុមារដែលបង្ហាញនូវអនាគតភ្លឺស្វាងលើការសិក្សារៀនសូត្រ – ការអប់រំសាធារណៈកម្រិត **K-12** ជួយកសាងកម្លាំងពលកម្មក្នុងស្រុក និងក្នុងតំបន់ដើម្បីទាក់ទាញ និងការពារអាជីវកម្មដែលជំរុញឲ្យមានកំណើនសេដ្ឋកិច្ច។

### ការកាត់បន្ថយភាពក្រីក្រ

ការអប់រំ គឺជាឱកាសដ៏ល្អបំផុតក្នុងការលុបបំបាត់វដ្តនៃភាពក្រីក្រ ដែលយាយីដល់តំបន់ជាច្រើននៃសហគមន៍នៅក្នុងទីក្រុង **Philadelphia** របស់យើង។ ការស្រាវជ្រាវបង្ហាញថាសញ្ញាបត្រនៅវិទ្យាល័យគឺជាកត្តាជំរុញផ្នែកសេដ្ឋកិច្ច។ពលរដ្ឋដែលបញ្ចប់ការសិក្សាពីវិទ្យាល័យរកប្រាក់បានច្រើន និងចំណាយប្រាក់ច្រើន ដែលជាការរួមចំណែកដល់ភាពរុងរឿងរបស់បុគ្គល និងកំណើនសេដ្ឋកិច្ចប្រចាំទីក្រុង **Philadelphia**។

### តម្លៃលំនៅដ្ឋានមានភាពល្អប្រសើរជាងមុន

សម្រាប់ពលរដ្ឋភាគច្រើន លំនៅដ្ឋានរបស់ពួកគេ គឺជាទ្រព្យហិរញ្ញវត្ថុដ៏ធំបំផុតរបស់ពួកគេ។ សាលារៀនសាធារណៈរឹងមាំ អាចមានឥទ្ធិពលជាវិជ្ជាមានដល់តម្លៃលំនៅដ្ឋាន។

**សម្រាប់សេចក្ដីលម្អិតបន្ថែមទៀតស្ដីពីរបៀបតស៊ូមតិនៅក្នុងទីក្រុង Harrisburg ទៅលើ #fundourschools សូមចូលទៅកាន់ philasd.org/fundourschools**